# សុន្ទរកថា

# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# និង ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

# ថ្លែងក្នុង

# ពិធីបើក «សប្តាហ៍គាំពារសង្គម ២០២៣»

## រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២៣

- **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!**
- **សមាជិក-សមាជិកា នៃអង្គពិធី, ជាទីមេត្រី!**

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សជាអនេក ដោយបានចូលរួមជាអធិបតី ក្នុងពិធីបើក «**សប្តាហ៍គាំពារសង្គម**» ប្រចាំឆ្នាំ ២០២៣ ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, អ្នកនាង, កញ្ញា, សមាជិក-សមាជិកានៃអង្គពិធីទាំងមូល ដែលបានចំណាយពេលដ៏មមាញឹក ចូលរួមក្នុងកម្មវិធីដ៏មានសារៈសំខាន់ នាថ្ងៃនេះ ។

នេះ ជាឆ្នាំទី ២ ហើយ ដែលក្រុមប្រឹក្សាជាតិគាំពារសង្គម បានរៀបចំ «**សប្តាហ៍គាំពារសង្គម**» នេះឡើង ។ ដូចឆ្នាំមុនដែរ, «**សប្តាហ៍គាំពារសង្គម**» ជាវេទិកាមួយដែលត្រូវបានរៀបចំឡើង ដើម្បីពិភាក្សា និង ផ្លាស់ប្តូរយោបល់ ក្នុងកម្រិតគោលនយោបាយ ក៏ដូចជាពិភាក្សា និង ស្វែងរកយន្តការ និង ដំណោះស្រាយនានា រួមគ្នា រវាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល, តំណាងនិយោជក, កម្មករ-និយោជិត, អង្គការសង្គមស៊ីវិល, ដៃគូអភិវឌ្ឍន៍ និង ភាគីពាក់ព័ន្ធដទៃទៀត ក្នុងប្រព័ន្ធគាំពារសង្គម ។

មូលបទនៃ «**សប្តាហ៍គាំពារសង្គម**» របស់យើងនៅឆ្នាំ ២០២៣ នេះ ផ្តោតលើ **ការពង្រឹងប្រសិទ្ធភាព និង តម្លាភាពប្រព័ន្ធគាំពារសង្គមកម្ពុជា** បន្ទាប់ពីការផ្តោតលើមូលបទ **ឆ្ពោះទៅការ-**

**អភិវឌ្ឍប្រព័ន្ធគាំពារសង្គមសម្រាប់គ្រប់គ្នា** កាលពីឆ្នាំ ២០២២ ។ ការជ្រើសរើសយកមូលបទនេះ បង្ហាញយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង លើដំណើរការគ្រប់គ្រង និង ចាត់ចែងកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គមនីមួយៗ ។ គោលការណ៍នៃ ការពង្រឹងប្រសិទ្ធភាព និង តម្លាភាព ពិតជាមានសារៈសំខាន់ក្នុងការធានាថា, ទាំងថវិការដ្ឋ និង ថវិកាភាគទាន, ដែលបង់ដោយនិយោក និង កម្មករ-និយោជិត ត្រូវបានប្រើប្រាស់ ចំគោលដៅ និង មិនខ្ជះខ្ជាយ ។ ស្របពេលដែលការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា បាន និង កំពុងបោះជំហានទៅមុខកាន់តែប្រសើរ, ការពង្រឹងប្រសិទ្ធភាព និង តម្លាភាពសម្រាប់ ការគ្រប់គ្រង កាន់តែមានភាពចាំបាច់ឡើងថែមទៀត ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

ក្រោមការដឹកនាំដ៏ឈ្លាសវៃ, ប៊ិនប្រសប់, ម៉ឺងម៉ាត់ និង ប្រាកដនិយមរបស់ **សម្តេចអគ្គ-មហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, កម្ពុជាមាន សមត្ថភាពគ្រប់គ្រងសភាពការណ៍ទល់នឹងវិបត្តិនានាបានយ៉ាងល្អប្រសើរ និង បានកាត់បន្ថយ ផលប៉ះពាល់អវិជ្ជមាន ឱ្យនៅក្នុងកម្រិតអាចគ្រប់គ្រងបាន តាមរយៈការដាក់ចេញនូវវិធានការ អន្តរាគមន៍ចាំបាច់, ទាំងក្នុងផ្នែកបច្ចេកទេស និង ផ្នែកសង្គម-សេដ្ឋកិច្ច, ជាបន្តបន្ទាប់ ប្រកប ដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពខ្ពស់ ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២២, សេដ្ឋកិច្ចកម្ពុជាមាន កំណើនប្រមាណ ៥,២% ដែលជាកំណើនមួយខ្ពស់ បើធៀបនឹងកំណើនមធ្យមក្នុងតំបន់ និង ត្រូវបានព្យាករថា នឹងសម្រេចបានកំណើនប្រមាណ ៥,៦% ក្នុងឆ្នាំ ២០២៣ ដែលនិន្នាការនេះ បង្ហាញថា កម្ពុជាបាន និង កំពុងបោះជំហានទៅរកស្ថានភាពល្អប្រសើរ ដូចពេលមុនវិបត្តិនៃ ជំងឺកូវីដ-១៩ ទោះបីជាស្ថានភាពសេដ្ឋកិច្ចសកលនៅមានភាពស្រពិចស្រពិល ដោយសារការ-បន្តអូសបន្លាយនៃវិបត្តិនៅលើឆាកអន្តរជាតិក៏ដោយ ។

ទន្ទឹមនឹងការងើបឡើងនៃស្ថានភាពសេដ្ឋកិច្ចជាទូទៅនេះ ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម នៅកម្ពុជា ក៏បានបន្តបោះជំហានទៅមុខយ៉ាងប្រសើរផងដែរ ដូចដែលអង្គពិធីទើបបានជ្រាប តាមរយៈរបាយការណ៍របស់ **ឯកឧត្តម ចន ណារិទ្ធ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម** អម្បាញ់មិញ ។ ខ្ញុំសូមគូស បញ្ជាក់ថា វឌ្ឍនភាពដែលយើងសម្រេចបានទាំងនេះ កើតឡើងដោយការខិតខំរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាមួយនឹងការផ្តល់ជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍ ក៏ដូចជាការចូល រួមចំណែករបស់គ្រប់ភាគីពាក់ព័ន្ធ ក្រោមការចង្អុលបង្ហាញដោយផ្ទាល់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែល **សម្តេច** តែងតែចាត់ទុកការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ជាគោល-

នយោបាយអាទិភាពមួយរបស់រាជរដ្ឋាភិបាល នាពេលកន្លងទៅ, ក្នុងបច្ចុប្បន្ន និង សម្រាប់អនាគត ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

ប្រព័ន្ធគាំពារសង្គម ជាសសរស្តម្ភដែលរួមចំណែកយ៉ាងសំខាន់ ក្នុងការកសាងសង្គមមួយ ប្រកបដោយភាពសុខដុម និង ជាមូលដ្ឋានគ្រឹះសម្រាប់ទ្រទ្រង់ និង អភិវឌ្ឍប្រទេសឱ្យមានភាពធន់រឹងមាំ, និរន្តរភាព, សមធម៌, បរិយាបន្ន និង ជួយឱ្យសង្គមជាតិអាចឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជ-រដ្ឋាភិបាល ។ ក្នុងន័យនេះ, ការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម មិនត្រឹមតែត្រូវការជាចាំបាច់នូវកិច្ចសហការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងត្រូវការជាចំបាច់ផងដែរនូវការកសាងយន្តការអភិបាលកិច្ចមួយដែលមានភាពរឹងមាំ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍តម្លាភាព និង គណនេយ្យភាព ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និង និរន្តរភាព ។

ជាក់ស្តែង, **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥** បានកំណត់យកគោលការណ៍អភិបាលកិច្ចល្អ ជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងប្រព័ន្ធគាំពារសង្គមតាមរយៈការកំណត់ឱ្យមានការបែងចែកមុខងាររបស់ស្ថាប័នពាក់ព័ន្ធជា ៣ កម្រិត គឺ៖ កម្រិតគោលនយោបាយ, កម្រិតនិយ័តករ និង កម្រិតប្រតិបត្តិករ ក្នុងគោលដៅធានាឱ្យមានប្រតិតុ-ល្យការសម្រាប់ប្រព័ន្ធទាំងមូល ។

បន្ទាប់ពីត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៧, **ក្រុមប្រឹក្សាជាតិគាំពារសង្គម** បានបំពេញតួនាទីជាសេនាធិការតែមួយរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ និង សម្របសម្រួលលើការ-រៀបចំគោលនយោបាយ ខណៈដែលការកែទម្រង់ស្ថាប័នពាក់ព័ន្ធ ក៏ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ដូចជា៖ (១).ការរៀបចំរចនាសម្ព័ន្ធថ្មីរបស់ **បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)**; (២).ការបង្កើត និង ដាក់ឱ្យដំណើរការ **មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.)**; និង (៣).ការខិតខំកែទម្រង់ **ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល** ឱ្យក្លាយជាស្ថាប័នបញ្ជាក់ចំណាយសម្រាប់ប្រព័ន្ធថែទាំសុខភាពសង្គមទាំងមូល ។

មិនតែប៉ុណ្ណោះ, រាជរដ្ឋាភិបាលក៏បានបង្កើត និង ដាក់ឱ្យដំណើរការ **និយ័តករសន្តិសុខសង្គម** ដែលជាសេនាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីធ្វើនិយ័តកម្ម និងត្រួតពិនិត្យលើប្រតិបត្តិការ ក្នុងប្រព័ន្ធសន្តិសុខសង្គមផងដែរ ។ វត្តមានរបស់និយ័តករសន្តិសុខសង្គម មានសារៈសំខាន់ណាស់ ក្នុងការធានាថា កិច្ចដំណើរការគ្រប់គ្រង និង ការចាត់ចែងរបបសន្តិសុខសង្គមនានា ត្រូវបានអនុវត្តប្រកបដោយភាពត្រឹមត្រូវ, តម្លាភាព និង គណនេយ្យភាព

ចំពោះសាធារណជន, ជាពិសេស ចំពោះនិយោជក និង កម្មករ-និយោជិត ដែលមានកាតព្វកិច្ចបង់ភាគទានចូលទៅក្នុងមូលនិធិរួមគ្នា ។ មួយវិញទៀត, និយ័តកម្មនៃប្រព័ន្ធសន្តិសុខសង្គមក៏មានភាពចាំបាច់ និង មានសារៈសំខាន់យ៉ាងខ្លាំងផងដែរ សម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង ការធានាស្ថេរភាពនៃប្រព័ន្ធហិរញ្ញវត្ថុរបស់ជាតិ ។ ថ្មីៗនេះ, រាជរដ្ឋាភិបាលទើបបានអនុម័ត **អនុក្រឹត្យស្ដីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម** ដើម្បីផ្ដល់មូលដ្ឋានគ្រឹះសម្រាប់ការចាប់ផ្ដើមបំពេញការងាររបស់និយ័តករសន្តិសុខសង្គម ។ ការធ្វើនិយ័តកម្មលើប្រព័ន្ធសន្តិសុខសង្គមជាប្រធានបទសំខាន់មួយរបស់ **«សប្ដាហ៍គាំពារសង្គម»** របស់យើងក្នុងឆ្នាំនេះ ដែលខ្ញុំសូមលើកទឹកចិត្ត ឱ្យមានការពិភាក្សាលើប្រធានបទនេះឱ្យបានផុសផុល ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

សម្រាប់ឆ្នាំ ២០២៣ នេះ, រាជរដ្ឋាភិបាលនឹងបន្តពង្រឹងប្រព័ន្ធគាំពារសង្គមទាំងមូលឱ្យកាន់តែល្អប្រសើរ ។ ទោះបីបច្ចុប្បន្ន ឥទ្ធិពលនៃជំងឺកូវីដ-១៩ បានថមថយក៏ដោយ, ក៏ប៉ុន្តែវិបាកអវិជ្ជមានលើស្ថានភាពសង្គម-សេដ្ឋកិច្ច និង ជីវភាពរស់នៅរបស់ប្រជាជន នៅតែមានគួបផ្សំនឹងជម្លោះ រវាងរុស្ស៊ី និង អ៊ុយក្រែន ដែលបានធ្វើឱ្យកម្ពុជាទទួលរងនូវសម្ពាធនៃការឡើងថ្លៃទំនិញ និង ភាពមិនប្រាកដប្រជាជាច្រើន ។ ក្នុងបរិការណ៍នេះ, ខ្ញុំសូមប្រកាសបញ្ជាក់ជាថ្មីថា រាជរដ្ឋាភិបាលសម្រេចបន្តអនុវត្ត **កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩** ក្នុងឆ្នាំ ២០២៣ ទៀត ដើម្បីបន្តជួយគាំទ្រគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងដំណាក់កាលនៃការស្ដារជីវភាពឡើងវិញ ។ កម្មវិធីនេះត្រូវបានអនុវត្តអស់ **៣១ ខែ** រួចមកហើយ និង បានផ្ដល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ចំនួនប្រមាណជាង **៧០ ម៉ឺនគ្រួសារ** ដែលមានសមាជិកចំនួនប្រមាណ **២,៧ លាននាក់** នៅទូទាំងប្រទេស ដោយបានប្រើប្រាស់ថវិកាជាតិសុទ្ធសាធ សរុបចំនួនប្រមាណ **៩៣២ លានដុល្លារអាមេរិក** ។

លើសពីនេះ, **គ្រួសារងាយរងហានិភ័យ** ដែលមានជីវភាពក្បែរនឹងបន្ទាត់នៃភាពក្រីក្រ ក៏ត្រូវបានគិតគូរផងដែរ ដោយរាជរដ្ឋាភិបាលបានដាក់ចេញ នូវកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ ក្នុងអំឡុងពេលរងសម្ពាធអតិផរណា និង រងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ ដើម្បីជួយរក្សាលំនឹងជីវភាពរបស់ពួកគាត់ ។ ជារួម, ក្នុងឆ្នាំ ២០២៣ នេះ, រាជរដ្ឋាភិបាលគ្រោងចំណាយថវិកាចំនួន **៤៦៥ លានដុល្លារអាមេរិក** សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ និង គ្រួសារងាយរងហានិភ័យ ។

ទន្ទឹមនឹងវឌ្ឍនភាព នៅក្នុងការអនុវត្តការងារកន្លងមក និង កិច្ចប្រឹងប្រែងជំរុញអនុវត្តទិសដៅរយៈពេលខ្លីចំពោះមុខ, រាជរដ្ឋាភិបាលក៏បាន និង កំពុងគិតគូរអំពីគោលដៅរយៈពេលវែង សម្រាប់បន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈកាន់តែគ្រប់ជ្រុងជ្រោយ, សមាហរណ, មានភាពធន់, និង ជាប្រព័ន្ធបែបស្វ័យប្រវត្តិកម្ម ក្នុងការទ្រទ្រង់សុខុមាលភាពប្រជាពលរដ្ឋទៅតាមដំណាក់កាលនៃវដ្តជីវិត, ជាពិសេស ក្នុងអំឡុងពេលមានវិបត្តិ ឬ គ្រោះអាសន្ន ។ ក្នុងន័យនេះ, ក្រុមប្រឹក្សាជាតិគាំពារសង្គមកំពុងរៀបចំធ្វើបច្ចុប្បន្នភាព **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥** ឱ្យកាន់តែមានភាពល្អប្រសើរ ដែលជាគុជធុំសំខាន់ៗនៃក្របខណ្ឌគោលនយោបាយជាតិថ្មី នឹងផ្តោតលើចំណុចសំខាន់ចំនួន ៥ ជាអាទិ៍៖

- **ទី ១.** ការគិតគូរពង្រីកវិសាលភាពកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គមជាជំហានៗ ដោយផ្អែកលើភាពទ្រទ្រង់បាននៃថវិកា (ទាំងថវិការដ្ឋ និង ថវិកាភាគទាន);
- **ទី ២.** ការធ្វើស្ថាប័នូបនីយកម្មយន្តការឆ្លើយតបនឹងគ្រោះអាសន្ន;
- **ទី ៣.** ការធ្វើឌីជីថលូបនីយកម្មនូវនីតិវិធីអនុវត្ត;
- **ទី ៤.** ការពង្រឹងយន្តការតាមដាន និង វាយតម្លៃ; និង
- **ទី ៥.** ការពង្រឹងយន្តការបញ្ជ្រាបចំណេះដឹង, ទំនាក់ទំនងសាធារណៈ, ទំនាក់ទំនងរវាងស្ថាប័ន និង ការផ្សព្វផ្សាយ ។

បន្ថែមលើការធ្វើបច្ចុប្បន្នភាពក្របខណ្ឌគោលនយោបាយនេះ, ក្រុមប្រឹក្សាជាតិគាំពារសង្គម ក៏បាន និង កំពុងរៀបចំឯកសារគោលនយោបាយគាំទ្រមួយចំនួនទៀត រួមមាន៖

១.ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល;
២.ផែនការយុទ្ធសាស្ត្រស្តីពីការពង្រឹងការចុះបញ្ជីរបបសន្តិសុខសង្គម;
៣.កម្មវិធីជាតិជំនួយសង្គមក្នុងក្របខណ្ឌកញ្ចប់គ្រួសារ; និង
៤.ក្របខណ្ឌកិច្ចគាំពារសង្គមដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន ជាដើម ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

ការរៀបចំ «**សប្តាហ៍គាំពារសង្គម**» ឆ្នាំ ២០២៣ នេះ ក៏ជាផ្នែកមួយនៃការចូលរួមពង្រឹងគោលការណ៍អភិបាលកិច្ចល្អ ក្នុងប្រព័ន្ធគាំពារសង្គមផងដែរ ។ ការបង្កើតឱកាសឱ្យអ្នករៀបចំគោលនយោបាយ បានស្តាប់កិច្ចពិភាក្សា និង ទទួលដឹងឮ អំពីលទ្ធផលនៃការដាក់ចេញនូវគោលនយោបាយនានា ជាធាតុចូលដ៏សំខាន់សម្រាប់ការគិតគូររៀបចំអនាគត ឱ្យកាន់តែប្រសើរ ។ ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម, ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ក្រសួង-ស្ថាប័ន,

ដៃគូអភិវឌ្ឍន៍ និង ភាគីពាក់ព័ន្ធទាំងអស់ ចូលរួមផ្តល់យោបល់ ក្នុងន័យស្ថាបនា, ទាំងលើគោលនយោបាយគាំពារសង្គម, និយាយជារួម, និង លើការអនុវត្តរបបសន្តិសុខសង្គម ឬ កម្មវិធីជាតិជំនួយសង្គមជាក់លាក់ណាមួយ, និយាយដោយឡែក, ដើម្បីឱ្យស្ថាប័នទទួលបន្ទុកអនុវត្ត មានលទ្ធភាពពិនិត្យ និង ពិចារណាកែតម្រូវភាពខ្វះចន្លោះនានា សំដៅធានាឱ្យប្រព័ន្ធគាំពារសង្គមកម្ពុជា ក្លាយជាប្រព័ន្ធមួយដែលមានប្រសិទ្ធភាព, ចីរភាព, សមធម៌ និង បរិយាបន្ន ។

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមគូសរំលេចផងដែរថា ការពិនិត្យ និង ព្យាបាលកុមារ ប្រកបដោយគុណភាព និង ដោយមិនគិតថ្លៃ នៅមន្ទីរពេទ្យគន្ធបុប្ផា ក៏ជាផ្នែកមួយនៃការផ្តល់កិច្ចគាំពារសង្គម ដែលខ្ញុំសូមសម្តែងនូវការកោតសរសើរ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រីទាំងអស់ ចំពោះការចូលរួមបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា ក្នុងការរួមគ្នារក្សានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យនេះ ។ ក្នុងឱកាសដ៏ថ្លៃថ្លានេះ, ខ្ញុំសូមលើកទឹកចិត្តឱ្យមានការចូលរួមបរិច្ចាគនេះ កាន់តែសកម្មឡើងថែមទៀត ក្នុងស្មារតី **«ខ្មែរជួយខ្មែរ»** ដោយខ្លួនឯង ដើម្បីភាពញញឹមរបស់កុមារដែលជាអនាគតដ៏ភ្លឺស្វាងរបស់កម្ពុជា ។

មុននឹងបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រីទាំងអស់** ជាថ្មីម្តងទៀត សម្រាប់ការចូលរួមក្នុង «**សប្តាហ៍គាំពារសង្គម**» នាថ្ងៃនេះ និង សូមថ្លែងអំណរគុណដៃគូអភិវឌ្ឍន៍ និង ភាគីពាក់ព័ន្ធផងដែរ ដែលបានចូលរួមយ៉ាងសកម្មក្នុងការគិតគូររៀបចំ និង គាំទ្រវេទិកានេះ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា វេទិកានេះនឹងដំណើរការដោយរលូន និង ប្រកបដោយផ្លែផ្កា តាមការរំពឹងទុក ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យជូន **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រីទាំងអស់** ប្រកបដោយសុខភាពល្អបរិបូរណ៍, មានសុភមង្គលក្នុងក្រុមគ្រួសារ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពពេញលេញទូទាំងផ្ទៃប្រទេស ដែលនាំមកជូនប្រជាជន និង ប្រទេសជាតិយើងដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ខ្ញុំសូមប្រកាសបើកជាផ្លូវការ «**សប្តាហ៍គាំពារសង្គម ២០២៣**» ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ** !